**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# “សេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាលរបស់កម្ពុជា គំរាមកំហែងដល់សង្គមស៊ីវិលដែលសេរី និងឯករាជ្យ” - ជំនាញការរបស់អង្គការសហប្រជាជាតិជំរុញឲ្យព្រឹទ្ធសភាបដិសេធច្បាប់នេះ

ទីក្រុងហ្សឺណែវ (១៥ កក្កដា ២០១៥) - ជំនាញការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លោក ម៉ៃណា គីអៃ (Maina Kiai) នៅថ្ងៃនេះ អំពាវនាវឲ្យព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ដែល “គំរាមកំហែងយ៉ាងច្បាស់លាស់ដល់ការបន្តអត្ថិភាពនៃសង្គមស៊ីវិលដែលសេរី និងឯករាជ្យក្នុងប្រទេសកម្ពុជា។”

សេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវពិនិត្យដោយព្រឹទ្ធសភានាពេលឆាប់ៗនេះ បន្ទាប់ពី រដ្ឋសភាជាតិកម្ពុជាបានអនុម័ត កាលពីថ្ងៃចន្ទ ទី១៣ ខែកក្កដា កន្លងមកនេះ។ សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តដោយឯកច្ឆន្ទ ដោយសមាជិកសភា ៦៨ រូប របស់គណបក្សកំពុងកាន់អំណាច ខណៈដែលសមាជិកសភា ៥៥ រូប របស់គណបក្សប្រឆាំងបានធ្វើពហិការមិនចូលរួមបោះឆ្នោត។

អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម បានក្រើនរំឭកថា “ប្រសិនបើ សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តមែននោះ ក្រុមណាមួយដែលតស៊ូមតិដើម្បីសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន និងអភិបាលកិច្ចល្អ អាចនឹងត្រូវបានបិទ និងជាប់បទល្មើស។ នៅទីបំផុត ច្បាប់នេះនឹងមានផលប៉ះពាល់ដ៏មហន្តរាយមួយដល់ការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាតាមបែបប្រជាធិបតេយ្យក្នុងការបន្តអភិវឌ្ឍប្រទេសរបស់ខ្លួន”។

លោក គីអៃ បានមានប្រសាសថា៖ “ខ្ញុំសូមជំរុញឲ្យព្រឹទ្ធសភាបដិសេធទាំងស្រុងនូវសេចក្តីព្រាងច្បាប់នេះ ដោយហេតុថា ច្បាប់នេះនៅមានកម្រិតទាបជាងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលគ្រប់គ្រងសេរីភាពបង្កើតសមាគម ឆ្ងាយណាស់ ជាពិសេស មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ដែលកម្ពុជាយល់ព្រមគោរពតាមនៅឆ្នាំ១៩៩២នោះ”។

អ្នករាយការណ៍ពិសេសបានគូសបញ្ជាក់ថា ស្របតាមសេចក្តីព្រាងច្បាប់នេះ អាជ្ញាធរអាចលុបឈ្មោះពីបញ្ជីនូវសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ប្រសិនបើ អាជ្ញាធរទាំងនោះចាត់ទុកសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសទាំងនេះ ថាមិនមាន “អព្យាក្រឹត្យភាពខាងនយោបាយ”។ អាជ្ញាធរទាំងនោះ អាចបដិសេធស្រដៀងគ្នានេះដែរនូវការចុះបញ្ជី ដោយឈរលើមូលដ្ឋានស្រពិចស្រពិលថា គោលបំណង និងគោលដៅរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល “បង្កគ្រោះថ្នាក់ដល់សន្តិសុខ ស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលប្រតិបត្តិការដោយមិនមានការចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា នឹងប្រឈមមុខនឹងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

លោក គីអៃ បានសង្កត់ធ្ងន់ថា "បញ្ហាព្រួយបារម្ភណ៍ដែលមានកម្រិតស្មើគ្នា គឺការពិតដែលថា មិនមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងតម្លាភាព ជាមួយសង្គមស៊ីវិលនៅទូទាំងដំណើរការធ្វើសេចក្តីព្រាងនេះឡើយ។ ទោះបីជាមានការស្នើសុំម្តងហើយម្តងទៀតពីភាគីពាក់ព័ន្ធជាច្រើនក៏ដោយ ក៏សេចក្តីព្រាងនេះមិនត្រូវបានចេញផ្សាយជាសាធារណៈអស់រយៈពេលជាច្រើនខែ រហូតទាល់តែក្រោយពេលអត្ថបទនេះត្រូវបានអនុម័តរួចទៅហើយដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដាក់ជូនរដ្ឋសភា ទើបអត្ថបទនេះបានចេញផ្សាយជាសាធារណៈ។ "សិក្ខាសាលាថ្នាក់ជាតិស្តីពីការយល់ដឹងអំពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)" មានរយៈពេលកន្លះថ្ងៃ ដែលបានប្រារព្ធធ្វើឡើងដោយរដ្ឋសភានៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ មិនបានអនុញ្ញាតឲ្យមានការផ្លាស់ប្តូរមតិយោបល់ជាសារវន្ត ប្រកបដោយអត្ថន័យ ទៅលើខ្លឹមសារលម្អិតនៃសេចក្តីព្រាងនេះឡើយ"។

ជំនាញការសិទ្ធិមនុស្សបានសង្កត់ធ្ងន់ថា "តម្លាភាព ការចូលរួមជាសាធារណៈ និងគណនេយ្យភាព គឺជាមូលដ្ឋានគ្រឹះនៃដំណើរការនីតិបញ្ញត្តិណាមួយនៅក្នុងសង្គមប្រជាធិបតេយ្យ"។

អ្នករាយការណ៍ពិសេសបានកត់សម្គាល់ថា "វាច្រើនលើកមកហើយដែលពីមុនមិនធ្លាប់មានទេ ខ្ញុំសូមផ្តល់ជូនជាថ្មីម្តងទៀតនូវការជ្រោមជ្រែងរបស់ខ្ញុំដល់រដ្ឋាភិបាល និងអ្នកតាក់តែងច្បាប់ ដែលខ្ញុំបានធ្វើឡើងជាច្រើនលើកច្រើនសារមកហើយ ចាប់តាំងពីដើមអាណត្តិរបស់ខ្ញុំនៅក្នុងឆ្នាំ២០១១ ដើម្បីជួយធានាថា សេចក្តីព្រាងច្បាប់នេះ អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។ "វាមិនទាន់យឺតពេលទេដើម្បីផ្លាស់ប្តូរទិសដៅនៃដំណើរការសកម្មភាពនេះនោះ"។

សំណើសុំឲ្យមានការផ្លាស់ប្តូរនាពេលបច្ចុប្បន្នរបស់ លោក គីអៃ ត្រូវបានគាំទ្រដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស លោក មីសែល ហ្វសត៍ (Michel Forst) និងជាអ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាព ឬគំនិត និងការសម្តែងមតិ លោក ដាវីដ កៃយេ (David Kaye)។

**(*)** *ដើម្បីផ្នែកមើលកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាល សូមចូលទៅកាន់៖*
http://www.ohchr.org/EN/ProfessionalInterest/Pages/CESCR.aspx

## ចប់

*លោក **ម៉ៃណា គីអៃ** (Mr. Maina Kiai) (កេនយ៉ា) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសដំបូងគេ ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ក្នុងខែឧសភា ឆ្នាំ២០១១។ លោក គីអៃ បាននិងកំពុងកាន់មុខតំណែងជានាយកប្រតិបត្តិនៃក្រុមប្រឹក្សាគោលនយោបាយសិទ្ធិមនុស្សអន្តរជាតិ និងជាប្រធានគណៈកម្មការជាតិសិទ្ធិមនុស្សកេនយ៉ា និងជានាយកក្រុមអ្នកច្បាប់សិទ្ធិមនុស្សអន្តរជាតិប្រចាំអាហ្វ្រិក ហើយនិងនាយកអង្គការលើកលែងទោសអន្តរជាតិប្រចាំអាហ្វ្រិក។*

*អ្នករាយកាណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។*

*ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។ ដើម្បីស្វែងយល់ថែមទៀត សូមចូលទៅកាន់៖*

***សេរីភាពក្នុងការជួបប្រជុំ៖***
*http://www.ohchr.org/EN/Issues/AssemblyAssociation/Pages/SRFreedomAssemblyAssociationIndex.aspx*

***អ្នកការពារសិទ្ធិមនុស្ស៖***
*http://www.ohchr.org/EN/Issues/SRHRDefenders/Pages/SRHRDefendersIndex.aspx*

***សិទ្ធិមនុស្សនៅកម្ពុជា៖***
*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក៖ ហ្គីល្លេម ផ្វេហ្វល្លេ (Guillaume Pfeifflé) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៤ / អ៊ីម៉ែល gpfeiffle@ohchr.org) ឬសរសេរមកកាន់ freeassembly@ohchr.org.*

*សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមក ឈ្មោះ សាបៀរ សែលាយ៉ា (Xabier Celaya) សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្តាញព័ត៌មានសង្គម ៖**

ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights

ទ្វីតធ័៖ http://twitter.com/UNrightswire

ហ្គោហ្គីល៖ **Google+** gplus.to/unitednationshumanrights

យូធូប៖ http://www.youtube.com/UNOHCHR

បរិយាយសាច់រឿង ៖ http://storify.com/UNrightswire